# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង

រោងចក្រ ហ៊ុង ហុីង មេថល មេនូហ្វេកធើរី ( ខេមបូឌា) ឯ.ក

ជាមួយសហជីព និង តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ

អាសយដ្ឋាន ភូមិ បូរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

នៅថ្ងៃទី០៨ ខែ មករា ឆ្នាំ ២០២៤ វេលាម៉ោង ១២:០០នាទី

មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ និងតំណាងកម្មករ-និយោជិត

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃរោងចក្រដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះរោងចក្រ សម្រេចចិត្តព្យួរកិច្ចសន្យារការងាររបស់កម្មករ-និយោជិតចំនួន ៨៤ នាក់(ស្រី៣៦ នាក់)ក្នុងចំណោម កម្មករ-និយោជិតសរុបចំនួន៧៨៧ នាក់(ស្រី៣៥៨ នាក់) ។រយៈពេល ១៥ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៤ ។ហើយក្នុងអំឡុងពេលព្យួរការងារនេះកម្មករ-និយោជិតបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ ៣០ ដុល្លា តាម សណាន020/23 ចុះថ្ងៃទី 15 មីនា ២០២៣។

ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ និងបើកជូនបងប្អូនកម្មករនិយោជិត នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៤។

អង្គប្រជុំបានចប់នៅវេលាម៉ោង ០១:០០នាទី នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃ....០៩កើត.....ខែ..មិគសិរ ឆ្នាំថោះ ចត្វាស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី..១៩. ខែ...មករា.. ឆ្នាំ២០២៤

**សហជីព តំណាងកម្មករ-និយោជិត**

**តំណាងរោងចក្រ**